# COVID-19៖ ការធានារ៉ាប់រងលើអាជីវកម្ម

## ព័ត៌មានស្ដីពីការធានារ៉ាប់រងសម្រាប់អាជីវកម្ម

ម្ចាស់អាជីវកម្មនៅរដ្ឋ Washington ជាធម្មតាតែងទិញធានារ៉ាប់រងដើម្បីការពារខ្លួនឯងមិនឲ្យមានការខាតបង់ធ្ងន់ធ្ងរឡើយ។ តាមរយៈការផ្ទុះឡើងនូវវីរុសកូរ៉ូណា (COVID-19) ម្ចាស់អាជីវកម្មអាចសួរជាសំណួរថាតើគោលនយោបាយធានារ៉ាប់រងបច្ចុប្បន្នរបស់ពួកគេរ៉ាប់រងលើប្រភេទនៃការខាតបង់នេះដែរឬទេ។

### តើអ្នកត្រូវការការរ៉ាប់រងទៅលើអ្វីខ្លះ

ដើម្បីរ៉ាប់រងលើការខាតបង់អាជីវកម្មណាមួយ ដោយសារតែជំងឺឆ្លងណាមួយ ដូចជា COVID-19 នេះជាដើម អ្នកចាំបាច់ត្រូវមានការធានាបន្ថែមទៅលើគោលនយោបាយរបស់អ្នក។

សូមទាក់ទងទៅកាន់ភ្នាក់ងារធានារ៉ាប់រង ឬក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នកដោយផ្ទាល់ ដើម្បីស្វែងយល់ថាតើអ្នកមានការធានារ៉ាប់រងបន្ថែមនេះរួចរាល់ហើយឬនៅ។ ប្រសិនបើអ្នកមិនមានការធានារ៉ាប់រងបន្ថែមនេះទេ ហើយមានបំណងទិញធានារ៉ាប់រងនេះ សូមទាក់ទងទៅកាន់ភ្នាក់ងារឬក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក ដើម្បីពិនិត្យមើលថាតើអាចទិញវាបានដែរឬអត់។

ប្រសិនបើអ្នកមិនបានទិញធានារ៉ាប់រងបន្ថែមមុនពេលផ្ទុះឡើងនៃជំងឺនេះ ហើយអ្នកមានបំណងទិញវានោះ ក្រុមហ៊ុនធានារ៉ាប់រងអាចនឹងមិនចង់លក់ការធានានេះជូនដល់អ្នកឡើយ។

## ការធានារ៉ាប់រងលើការលុបចោលការរៀបចំកម្មវិធីអ្វីមួយ

ទីតាំងនៃការរៀបចំកម្មវិធី ជាធម្មតាតម្រូវឲ្យបុគ្គល និងក្រុមហ៊ុនដែលធ្វើការកក់ទុកកម្មវិធីណាមួយដែលបានរៀបចំឡើងនោះមានការរ៉ាប់រងលើការលុបចោលការរៀបចំកម្មវិធីអ្វីមួយ។ ការធានារ៉ាប់រងលើការផ្ទុះឡើងនៃជំងឺឆ្លងនានា ជាធម្មតាមិនរួមបញ្ចូលនូវគោលនយោបាយធានារ៉ាប់រងលើការលុបចោលការរៀបចំកម្មវិធីណាមួយឡើយ។ ការធានារ៉ាប់រងប្រភេទនេះ រ៉ាប់រងតែទៅលើប្រភេទគ្រោះថ្នាក់ទាំងនេះតែប៉ុណ្ណោះ៖

- អាកាសធាតុមិនល្អ
- គ្រោះធម្មជាតិ
- វិវាទការងារ
- សកម្មភាពភេរវកម្ម
- ករណីមិនផ្ដល់ការទូទាត់ថ្លៃឈ្នួល
- ករណីមិនបង្ហាញខ្លួននៅតុលាការ

### តើអ្នកត្រូវការការរ៉ាប់រងទៅលើអ្វីខ្លះ

អ្នកអាចទិញការធានាបន្ថែមទៅលើគោលនយោបាយធានារ៉ាប់រងលើការលុបចោលការរៀបចំកម្មវិធីណាមួយរបស់អ្នក ដើម្បីរ៉ាប់រងលើការលុបចោលកម្មវិធីអ្វីមួយដោយសារតែជំងឺឆ្លងណាមួយ។ ប្រសិនបើអ្នកធានារ៉ាប់រងរបស់អ្នកមិនផ្ដល់ជូនការធានាប្រភេទនេះទេ អ្នកគប្បីត្រូវស៊ើបសួរទិញពីអ្នកធានារ៉ាប់រងផ្សេងទៀត។

ត្រូវដឹងថាប្រសិនបើអ្នកមិនបានទិញការធានាបន្ថែមណាមួយនៅមុនពេលផ្ទុះឡើងនៃជំងឺនេះទេ ហើយអ្នកចាំបាច់ត្រូវលុបចោលកម្មវិធីអ្វីមួយ អ្នកធានារ៉ាប់រងមិនអាចចុះកាលបរិច្ឆេទមុនពេលកំណត់ទៅលើគោលការណ៍ធានាណាមួយដែលផ្ដល់ការធានាសម្រាប់ការលុបចោលកម្មវិធីនោះឡើយ។ អ្នកធានារ៉ាប់រង ក៏អាចនឹងគ្មានបំណងលក់ការធានារ៉ាប់រងប្រភេទនេះដែរ។

**សម្គាល់៖** Office of the Insurance Commissioner (ការិយាល័យស្នងការធានារ៉ាប់រង) មិនមានសិទ្ធិក្នុងការតម្រូវឲ្យអ្នកធានារ៉ាប់រងលក់ការរ៉ាប់រង និងការធានាលើគោលនយោបាយជូនទៅដល់អតិថិជន។

**តើមាន សំណួរអំពីការធានារ៉ាប់រងមែនទេ?**

**www.insurance.wa.gov**

**1-800-562-6900**

OFFICE of the INSURANCE COMMISSIONER WASHINGTON STATE

facebook.com/wsoic twitter.com/WA_OIC medium.com/commissioners-eye-on-insurance